# ដំណើរការនៃការស្នើសុំ
# ការបំពេញបែបបទនាំចេញ-នាំចូលផល-អនុផលព្រៃឈើ
# និងយថាប្រភេទផល-អនុផលព្រៃឈើអនុញ្ញាតអោយនាំចេញ-នាំចូល

ដំណើរការនៃការស្នើសុំ និងបំពេញបែបបទនាំចេញ-នាំចូលផល អនុផលព្រៃឈើចែកចេញជា ៥ ដំណាក់កាល ។ ពេលវេលាចាំបាច់ដើម្បីទទួលបាននូវការឆ្លើយតប ឬអាជ្ញាប័ណ្ណមានការប្រែប្រួលទៅតាមករណីនីមួយៗអាស្រ័យទៅតាមភាពស្រប ឬមិនស្របច្បាប់នៃផល អនុផលព្រៃឈើ និងលក្ខណៈគ្រប់គ្រាន់នៃសំណុំឯកសារដែលបានស្នើសុំ ។

## ១- ដំណើរការនៃការស្នើសុំគោលការណ៍-អាជ្ញាប័ណ្ណនាំចេញ-នាំចូល

| ជំហានទី ១ | ជំហានទី ២ | ជំហានទី ៣ | ជំហានទី ៤ | ជំហានទី ៥ |
|---|---|---|---|---|
| ការដាក់ពាក្យសុំ | ការពិនិត្យសំរេចរបស់អង្គភាព-ស្ថាប័នគ្រប់គ្រងវិស័យព្រៃឈើ | ការផ្តល់គោលការណ៍អនុញ្ញាតនាំចេញនាំចូល | ការផ្តល់អាជ្ញាប័ណ្ណនាំចេញ-នាំចូល | ការផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូននាំចេញ-នាំចូល |

| | |
|---|---|
| ជំហានទី ១ | **ការដាក់ពាក្យសុំ**<br>អ្នកស្នើសុំត្រូវដាក់ពាក្យស្នើសុំអនុញ្ញាតនាំចេញ-នាំចូលផលអនុផលព្រៃឈើនៅរដ្ឋបាលព្រៃឈើ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ។ ត្រូវភ្ជាប់មកជាមួយនូវពាក្យស្នើសុំ (ច្បាប់ដើម) ចំនួន ២ ច្បាប់ បញ្ជីរាយលំអិតមុខផល អនុផលព្រៃឈើចំនួន ២ ច្បាប់ វិក័យប័ត្រចំនួន ២ ច្បាប់ កិច្ចសន្យាប្រគល់ទទួលទំនិញចំនួន ១ ច្បាប់ វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីអាករលើតម្លៃបន្ថែម ប័ណ្ណប៉ាតង់ លិខិតប្រគល់សិទ្ធិ លិខិតបញ្ជាក់ប្រភពវត្ថុធាតុដើមស្របច្បាប់ ។ល។ |
| ជំហានទី ២ | **ការពិនិត្យសំរេចរបស់អង្គភាព-ស្ថាប័នគ្រប់គ្រងវិស័យព្រៃឈើ**<br>ទទួលបានពាក្យសុំ រដ្ឋបាលព្រៃឈើពិនិត្យលើសំណុំឯកសារស្នើសុំ និងផ្តល់មតិជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពិនិត្យសំរេច ។ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទធ្វើការសំរេច ឬសុំការពិនិត្យសំរេចបន្តពីទីស្តីការគណៈរដ្ឋមន្ត្រីទៅតាមគោលការកំណត់នៃច្បាប់ ។ |
| ជំហានទី ៣ | **ការផ្តល់គោលការណ៍អនុញ្ញាតនាំចេញនាំចូល**<br>គោលការណ៍អនុញ្ញាតអោយនាំចេញ-នាំចូលត្រូវបានផ្តល់ដោយទីស្តីការគណៈរដ្ឋមន្ត្រី ឬក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសុពលភាពរយៈពេលមួយឆ្នាំ ។ នៅពេលផុតសុពលភាព អ្នកស្នើសុំអាចដាក់ពាក្យស្នើសុំពន្យាបន្តដោយបញ្ជាក់ច្បាស់លាស់អំពីហេតុផលនៃការយឺតយ៉ាវ ឬខក |

| | |
|---|---|
| | ខាងក្នុងការនាំចេញ-នាំចូលផលិតផលរបស់ខ្លួន។ |
| **ជំហានទី ៤** | **ការផ្តល់អាជ្ញាប័ណ្ណនាំចេញ-នាំចូល**<br>អ្នកស្នើសុំអនុញ្ញាតនាំចេញ-នាំចូលផល អនុផលព្រៃឈើក្រោយពេលទទួលបានគោលការណ៍ខាងលើនេះរួច ត្រូវស្នើសុំអាជ្ញាប័ណ្ណនាំចេញ-នាំចូលតាមបរិមាណជាក់ស្តែងដែលស្នើសុំនាំចេញ-នាំចូលសំរាប់លើកទីមួយៗរហូតដល់អស់បរិមាណដែលទទួលបានការអនុញ្ញាតនៅក្នុងគោលការណ៍។ អាជ្ញាប័ណ្ណនាំចេញ-នាំចូលនេះនឹងត្រូវផ្តល់ជូនដោយក្រសួងពាណិជ្ជកម្មដោយមានចុះទិដ្ឋាការជាមុនដោយប្រធានរដ្ឋបាលព្រៃឈើ។ |
| **ជំហានទី ៥** | **ការផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូននាំចេញ-នាំចូល**<br>ដើម្បីដឹកជញ្ជូនទៅកាន់ច្រកនាំចេញបាន អ្នកនាំចេញត្រូវស្នើសុំលិខិតអនុញ្ញាតដឹកជញ្ជូនផល-អនុផលព្រៃឈើនាំចេញ-នាំចូលជាមុន។ ការស្នើសុំនេះត្រូវធ្វើរួមគ្នាជាមួយលិខិតស្នើសុំអាជ្ញាប័ណ្ណដោយដាក់ពាក្យសុំនៅរដ្ឋបាលព្រៃឈើ |

## ២. យថាប្រភេទផល-អនុផលព្រៃឈើអនុញ្ញាតអោយនាំចេញ-នាំចូល

យថាប្រភេទផល អនុផលព្រៃឈើអនុញ្ញាតអោយនាំចេញ-នាំចូល ការហាមឃាត់ លក្ខខណ្ឌចាំបាច់នៃការអនុញ្ញាតមានចែងលំអិតនៅក្នុងអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីយថាប្រភេទផល អនុផលព្រៃឈើអនុញ្ញាតអោយនាំចេញ-នាំចូល របស់រាជរដ្ឋាភិបាលកម្ពុជា។